**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ នៅលើផ្លូវលេខ៥
## ចំណុចភូមិជ្រៃបាក់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
## ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីរន្ធត់ និងសោកស្តាយយ៉ាងក្រៃលែង នៅពេលបានទទួលដំណឹងថា មានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍រថយន្តដឹកកម្មករបើកដល់ផ្លូវកោងដាច់រ៉ូទីលជ្រុលទៅបុកកម្មការិនីម្នាក់ដែលកំពុងឈរប៉ះម៉ូតូ និងហួសទៅបុកផ្ទះប្រជាពលរដ្ឋ កាលពីវេលាម៉ោង៦និង៤០នាទីព្រឹក ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ស្ថិតតាមផ្លូវជាតិលេខ៥ ចន្លោះគីឡូម៉ែត្រលេខ៨៣ និង៨៤ ចំណុចភូមិជ្រៃបាក់ ឃុំជ្រៃបាក់ ស្រុករលៀប្អៀរ ខេត្តកំពង់ឆ្នាំង ដែលបានបណ្តាលឱ្យកម្មការិនីចំនួន០១នាក់ បានស្លាប់ និងចំនួន ១៣នាក់ បានរងរបួស ក្នុងនោះរបួសស្រាលចំនួន១២នាក់ និងរបួសធ្ងន់ចំនួន០១នាក់។ អ្នករងរបួសទាំងនេះ បានទទួលការជួយសង្គ្រោះ ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយយកចិត្តទុកដាក់បំផុត។ គិតត្រឹមម៉ោង៩និង៣០នាទីព្រឹក ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៦ នេះកម្មកររងរបួសចំនួន១៣នាក់ បាននិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ឆ្នាំង។

ឆ្លៀតក្នុងឱកាសដ៏ក្រៀមក្រំនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមចូលរួមមរណៈទុក្ខចំពោះគ្រួសារកម្មការិនីដែលស្លាប់ និងសូមចែករំលែកនូវសេចក្តីសោកស្តាយ និងអាណិតស្រឡាញ់ជាទីបំផុតជាមួយក្រុមគ្រួសារ និងញាតិមិត្តទាំងអស់របស់ជនរងគ្រោះ ហើយសូមជូនពរដល់អ្នកដែលរងរបួសទាំងអស់ឆាប់បានជាសះស្បើយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តជួយដោះស្រាយទុក្ខលំបាករបស់បងប្អូនកម្មការិនី និងក្រុមគ្រួសារទៅតាមគោលរបបសន្តិសុខសង្គម របស់បេឡាជាតិរបបសន្តិសុខសង្គម។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៦